# តើអ្នកណាធំជាងគេក្នុងនគរស្ថានសួគ៌ ?

សូមបំពេញឯកសារចែកចាយនេះជាក្រុម ហើយពិភាក្សាចម្លើយចំពោះសំណួររបស់អ្នក ។

សូមសរសេរសកម្មភាពមួយចំនួនដែលអ្នកពេញចិត្ត ៖ ______________________________

- សូមរៀបរាប់ឈ្មោះបុគ្គលមួយចំនួន ដែលបានធ្វើយ៉ាងល្អក្នុងសកម្មភាពដែលអ្នកបានរៀបរាប់ខាងលើ ។ តើអ្វីដែលធ្វើឲ្យពួកគេធំជាងគេ ?

នៅពេលអ្នកបន្តសិក្សាព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះនៅក្នុងម៉ាកុស ១០សូមរកមើលនូវអ្វីដែលទ្រង់បង្រៀន ដែលធ្វើឲ្យមនុស្សម្នាក់ធំជាងគេពិតប្រាកដ ។

សូមអានម៉ាកុស ១០:៣៥-៣៧ហើយរកមើលនូវអ្វីដែលយ៉ាកុប និង យ៉ូហាន បានទូលសូមពីព្រះអង្គសង្គ្រោះ នៅពេលពួកគេបានធ្វើដំណើរឆ្ពោះទៅទីក្រុងយេរូសាឡិម ។

សំណើរបស់យ៉ាកុប និង យ៉ូហានចង់អង្គុយនៅខាងស្ដាំ និង ខាងឆ្វេងព្រះហស្តរបស់ព្រះអង្គសង្គ្រោះមានន័យថា ពួកគាត់ចង់បានទទួលសិរីល្អ និងកិត្តិយសកាន់តែខ្ពស់នៅក្នុងនគររបស់ព្រះ ជាងពួកសាវកដទៃៗទៀត ។ ម៉ាកុស ១០:៣៨-៤០កត់ត្រាថា ព្រះអង្គសង្គ្រោះបានពន្យល់ដល់យ៉ាកុប និង យ៉ូហានថា ពរជ័យនេះនឹងត្រូវបានប្រទានដល់អ្នកទាំងឡាយដែលត្រៀមខ្លួនដើម្បីទទួលវា ។

សូមអានម៉ាកុស ១០:៤១ហើយរកមើលរបៀបដែលសិស្សផ្សេងទៀតបានឆ្លើយតបចំពោះសំណើរបស់យ៉ាកុប និងយ៉ូហាន ។

- ហេតុអ្វីអ្នកគិតថា សិស្សដទៃទៀតមិនរីករាយជាមួយយ៉ាកុប និងយ៉ូហាន ?

សូមអានម៉ាកុស ១០:៤២-៤៥រកមើលថាព្រះអង្គសង្គ្រោះបានបង្រៀនអ្វីខ្លះដល់ពួកសាវករបស់ទ្រង់អំពីភាពធំជាងគេ ។

សូមបំពេញសេចក្ដីថ្លែងការណ៍ដូចខាងក្រោមដោយផ្អែកទៅលើអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនអំពីភាពធំជាងគេពិតប្រាកដ ៖

**ដើម្បីធំជាងគេពិតប្រាកដយើងត្រូវតែ** ______________________________.

នៅក្នុងខ ៤៥ពាក្យ*បម្រើ*មានន័យថា ផ្ដល់ការមើលថែ ការលួងលោមចិត្ត ជួយ និងការគាំទ្រដល់អ្នកដទៃ ។

- ហេតុអ្វីក៏មនុស្សម្នាក់ដែលបម្រើ ហើយធ្វើការងារបម្រើដល់អ្នកដទៃ ( ដូចព្រះអង្គសង្គ្រោះ ) ត្រូវបានចាត់ទុកថាធំជាងគេពិតប្រាកដ ?

- តើពេលណា ដែលនរណាម្នាក់បម្រើ និងមើលថែអ្នក ឬគ្រួសារអ្នក? ហេតុអ្វីក៏អ្នកគិតថា មនុស្សម្នាក់នោះធំជាងគេពិតប្រាកដ ?



© ឆ្នាំ ២០១៥ ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង ។